# រូបកាយរបស់ព្រះគ្រិស្ត

កូឡ .២:១៩...កាន់ជាប់តាមសិរសា..ដែលដោយសារសិរសា នោះរូបកាយទាំងមូល...បាន ចម្រើនឡើង ដោយសេចក្តីចម្រើនរបស់ព្រះ

នៅក្នុងគម្ពីរសញ្ញាថ្មីបញ្ជាក់ប្រាប់យើងយ៉ាងច្បាស់ថា ក្រុមជំនុំជារូ យកាយរបស់ព្រះគ្រិស្ត (អភ .១: ២២-២៣, រ៉ូម ១២៥ ,១ ករ .១២: ១២)។ មុខងាររបស់រូបកាយ គឺសម្រាប់សម្តែងចេញព្រះគ្រិស្តដ៏ពេញលេញ ។

## រូបកាយរបស់ព្រះគ្រិស្តជីថាការសម្តែងមេញរបស់ព្រះគ្រិស្ត

ការចម្រើនធំឡើងរបស់រូបកាយ ពឹងផ្អែកទៅលើអ្វីដែលចេញមកពី ព្រះគ្រិស្តតជាសិរសា ដូចជារុក្ខជាតិចម្រើនធំឡើងដោយពឹងផ្អែកទៅលើអ្វីដែលចេញមកពីដី ចូលទៅក្នុងរុក្ខជាតិនោះ ។ បើរុក្ខជាតិមិនស្រូបសារជាតុចិញ្ចឹមពីដីទេ រុក្ខជាតិមិនអាចចម្រើនធំឡើងបានឡើយយ៉ាងណាមិញ បើយើងមិនបានទទួលអ្វីចេញមកពីព្រះគ្រិស្តជាសិរសាទេនោះរូបកាយមិនអាចចម្រើនធំឡើងបានឡើយ ។ ដូច្នេះ ការកាន់តាមសិរសា គឺស្មើនឹងបានចាក់ឫសនៅក្នុងព្រះគ្រិស្តជាដី (២៧) ។

ដោយព្រោះព្រះជាម្ចាស់ប្រទានការចម្រើនធំឡើងតាមរបៀបនោះ យើងត្រូវការពេលវេលាដើម្បីស្រូបយកទ្រង់ ។ ទំនាក់ទំនងរបស់យើងជាមួយនឹងព្រះអង្គ មិនគួរធាប់លឿនពេកទេ ប្រសិនបើលឿនពេកយើងនឹងមិនអាច ស្រូវបយកភាពបរិបូរណ៌របស់ទ្រង់បាន ឡើយ ។ យើងត្រូវការមានពេលវេលាគ្រប់គ្រាន់ដើម្បីអធិដ្ឋាន ។ ប្រសិនបើយើងចង់ចម្រើនធំឡើងយើង យើងត្រូវការចូលទៅក្នុងព្រះបន្ទូល ព្រមទាំងហ្វឹកហាត់ប្រើវិញ្ញាណរបស់យើងអធិដ្ឋាន ដើម្បីទទួលយកព្រះអង្គរាល់ៗថ្ងៃ ជាពិសេសរៀងរាល់ពេលព្រឹកយើងត្រូវមានពេលវេលាគ្រប់គ្រាន់ ដើម្បីស្រូបយកព្រះអង្គ ។

## កសាងរូបកាយរបស់ព្រះគ្រិស្តចោយការចម្រើនចំឡើងនៅក្នុងជីវិត

ជាដំបូងពួកបរិសុទ្ធត្រូវចម្រើនធំឡើងនៅក្នុងទ្រង់ជាសិរសា ខាងឯគ្រប់ការទាំងអស់ បន្ទាប់មកយើងនឹងមានការចិញ្ចឹមពីសិរសា ដូចបានបញ្ជាក់ដោយពាក្យ ផ្គត់ផ្គង់ឱ្យនៅក្នុងអេភេសូ ៤:១៦ ។ តាមរយៈការផ្គត់ផ្គង់ចេញពីសិរសា នោះរូបកាយចម្រើនធំឡើង ព្រមទាំងស្អាងខ្លួន (កសាង) ឡើង ក្នុងសេចក្តីស្រឡាញ់ ។ ប៉ុលបាននិយាយសង្កត់ធ្ងន់ថា យើងត្រូវការចម្រើនធំឡើង ពីព្រោះបើយើងមិនចម្រើនធំឡើងទេ ការកសាងក៏គ្មានដែរ។

## កសាងរូបកាយរបស់ព្រះគ្រិស្តឡើង ដោយការអធិប្បាយ

សាវកប៉ុលបានបង្រៀនថា យើងអាចអធិប្បាយបានទាំងអស់គ្នា (១ ករ .១៤៣១) ។ នេះជាខមួយដែលបញ្ជាក់ច្បាស់ជាងគេ នៅក្នុងព្រះគម្ពីរ ។ ខនេះនិយាយថា ពួកអ្នកជឿទាំងអស់មានសមត្ថភាពអាចអធិប្បាយបានគ្រប់គ្នា ។ ពាក្យថាសមត្ថភាពនៅត្រង់នេះ បញ្ជាក់អំពីលទ្ធភាពដែលបានពីកំណើតមក ប៉ុន្តែមានពួកបរិសុទ្ធជាច្រើនក្នុងចំណោមយើង នៅតែមានអារម្មណ៍ថា គ្រប់គ្នាអាចអធិប្បាយបានមែន លើកលែងតែពួកគេចេញ ។ ទោះជាយ៉ាងណាក៏ដោយ គ្មានការលើកលែងឡើយ ។ ប្រហែលជាយើងមិនពូកែវោហារទេ ប៉ុន្តែយើងនៅតែអាចអធិប្បាយបាន ។ព្រះអង្គចង់ឱ្យយើងរាល់គ្នានិយាយពីព្រោះដើម្បីកសាងរូបកាយផ្នែកជីវិតរបស់ព្រះគ្រិស្តយើងរាល់គ្នាត្រូវតែនិយាយ។

ដើម្បីអាចអធិប្បាយបាន មានចំណុចមួយចំនួនដែលយើងត្រូវធ្វើដោយខានមិនបាន: ទី ១ យើងត្រូវស្រឡាញ់ព្រះអង្គនិងប្រកបជាមួយព្រះអង្គ ។ យើងត្រូវតែរស់នៅចំពោះព្រះអង្គនិងធ្វើជាមនុស្សដែលរួមជាតែមួយនឹងទ្រង់ ។ ទី ២ យើងត្រូវចំណាយពេលរៀន សេចក្តីពិតដោយអានព្រះគម្ពីរឱ្យបានច្រើនព្រមទាំងសៀវភៅផ្នែកវិញ្ញាណផ្សេងៗទៀត ។ ទី៣ យើងត្រូវមានភាពបត់បែន ដើរយោងទៅតាមព្រះវិញ្ញាណ និងទទួលយកភាពស្រស់ថ្មីភ្លាមៗ រាល់ពេលរាល់វេលា ។ ទី៤ យើងត្រូវការរៀនឱ្យមាននិមិត្តខាងឯឋានសួគ៌ កាន់តែទូលំទូលាយ ដើម្បីស្គាល់ព្រះគ្រិស្តនិងក្រុមជំនុំ ហើយត្រូវជៀសវាងមានទស្សនៈ ឬនិមិត្តផ្ទាល់ខ្លួន ប៉ុន្តែត្រូវមាននិមិត្តដែលមកពីព្រះវិញ ។ ទី៥ យើងត្រូវចេះរៀបចំសម្រាប់អធិប្បាយ នៅក្នុងការដំណើរជីវិតប្រចាំថ្ងៃរបស់យើង ។

# យើងរាល់គ្នារួមមកជាតែមួយ

(អ. 1107)




២. នំប៉័ងនេះបានសម្តែងពីរូបកាយព្រះអង្គ
យើងបានរួមហូបរួមមានចំណែកក្នុងព្រះអង្គ
ដែលបានកាច់ចេញសម្រាប់ពួកបរិសុទ្ធ
ជាបន្ទាល់ថាយើងបានរួមគ្នាតែមួយ ។

៣. ពែងនិងនំប៉័ងដែលបានបម្រុងទុកទីនេះ
រួមទទួលព្រះពរគ្មានហេតុផលសម្អាងណា
ជាសម្គាល់ថាមិនអាចបែងចែងគ្នាបាន
គ្រាន់តែថ្លែងថាព្រះអង្គនិងខ្ញុំតែមួយ ។

៤. យើងរួមតែមួយគ្មានអ្នកណាអាចបំបែកបាន
កាយមួយពែងមួយយើងរាល់គ្នារួមហូបផឹកទ្រង់
ក្នុងភាពតែមួយយើងជារូបកាយព្រះគ្រិស្ត
ប្រាកដច្បាស់ថាពួកយើងគឺជាបន្ទាល់ ។

៥. ក្នុងភាពតែមួយយើងសែនរីករាយក្តីអំណរ
ក្នុងចំណោមយើងបានភ្លក់រសជាតិដ៏អស្ចារ្យ
ដែលជាព្រះពរព្រះអង្គទ្រង់សព្វព្រះទ័យ
ស្វាមីភរិយារួមគ្នាដ៏សែនរីករាយ ។